# ជូថានី

(១៩៣៦-១៩៧៥)

បណ្ឌិតសភាចារ្យ **ឃីងហុកឌី**

*កើតនៅថ្ងៃ១៥កក្កដា១៩៣៨ ក្នុងសង្កាត់កំពង់ឆ្នាំង ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។*

*លោកជាមន្ត្រីរាជការក្នុងក្របខណ្ឌក្រសួងមហាផ្ទៃមានឋានៈជាលេខាធិការ* (Secrétaire du Ministère de l’Intérieur) *ហើយបានធ្វើការនៅក្រសួងទីស្ដីការនាយករដ្ឋមន្ត្រី។ ក្រោយមកលោកបានជាប់កំណែនក្នុងកាតព្វកិច្ចចំពោះមន្ត្រីរាជការនៅវ័យក្មេងដែលត្រូវចូលបម្រើការក្នុងយោធាមួយរយៈពេលដោយទទួលឋានន្តរស័ក្តិទៅតាមឋានានុក្រមក្នុងក្រសួងដើម។ លោកបានទទួលសក្តិជាអនុសេនីយត្រីបម្រុង* (Officier de réserve) *ក្នុងក្រសួងការពារជាតិៗនេះបានបញ្ជូនលោកឲ្យទៅហ្វឹកហ្វឺនយុទ្ធសាស្ត្រជានាយទាហានដែលមានរយៈពេលហាត់រៀនក្នុងចំនួនវេលា៦ខែ។ តែលោកមិនបានរៀនជានាយទាហានចប់សព្វគ្រប់ព្រោះមានជម្ងឺ។ សាលាយោធាបានបញ្ជូនលោកទៅព្យាបាលខ្លួននៅមន្ទីរពេទ្យយោធាព្រះមុនីវង្សភ្នំពេញ។ បន្ទាប់ពីបានជាសះស្បើយលោកត្រូវគ្រូពេទ្យពិនិត្យកាយសម្បទាសាជាថ្មីមុននឹងអនុញ្ញាតឲ្យលោកត្រ*

ឡប់ទៅហាត់ហ្វឹកហ្វឺនបន្តផ្នែកយុទ្ធសាស្ត្រយោធាវិញ។ តែគ្រូពេទ្យឯកទេសទាហានពិនិត្យឃើញថាកាយសម្បទាលោកមិនគ្រប់គ្រាន់ក្នុងការបម្រើកងទ័ព ជាអនុសេនីយត្រីបម្រុងទេ។ ក្រសួងការពារជាតិក៏អនុញ្ញាតឲ្យលោក ត្រឡប់មកក្រសួងដើមលោកវិញ។

បន្ទាប់ពីឆ្នាំ១៩៧០ក្រោយពេលដែលកម្ពុជាដូររបបនយោបាយពីព្រះរាជាណាចក្រកម្ពុជាទៅជាសាធារណរដ្ឋខ្មែរ លោកក៏ចូលបម្រើកងទ័ព នៅក្នុងកងវិរសេនាធំលេខ១៣ក្នុងទីរួមខេត្តកំពង់ស្ពឺ ជាវរសេនីយ៍ត្រី (ស័ក្តិ២) កាន់ខាងការិយាល័យទី៥ដែលជាការិយាល័យស៊ើបអង្កេតពត៌មាននិងឃោសនាក្រោមមេបញ្ជាការឧត្តមសេនីយ៍ត្រី ព្រះអង្គម្ចាស់ **នរោត្តមចន្ទរង្សី**។[1] ឋានន្តរសក្តិជាវរសេនីយត្រីនេះគឺជាឋានន្តរសក្តិពិសេសដែលទ្រង់នរោត្តមចន្ទរង្សីប្រគល់ជូនអ្នកដែលធ្លាប់ជួយទ្រង់នៅគ្រាក្រលំបាក គឺពេលដែលលោកជាប់ពន្ធនាគារនាឆ្នាំ១៩៥២ ទ្រង់បានសរសេរប្រលោមលោកជាច្រើននាវេលានោះហើយ ដែលលោក ជូ ថានី បានយកទៅបោះពុម្ពផ្សាយ ក្រោមរហស្សនាម **ជាលី** ឬ ចៅ**ក្រឹស្នា** ឬ ចៅ**ក្រឹស្នា ជាលី**[2]។

[1] ពត៌មានបានមកពីលោកហេងអ៊ីវជួ ជាមិត្តជិតស្និទ្ធនឹងលោក ជូថានីផ្ទាល់ និងពីបណ្ឌិតសភាចារ្យរស់ចន្ទ្រាបុត្រ។ សូមអរគុណលោកទាំង២ដែលផ្តល់ពត៌មាននេះ។

[2] សូមអានបន្ថែមសៀវភៅជាភាសាបារាំងដោយ ឃីងហុកឌី, *Ecrivains et expressions littéraires du Cambodge au XXème siècle*, Paris, L'Harmattan, 1993។

លោកមានគេហដ្ឋាននៅក្នុងសង្កាត់ទឹកល្អក់នៅចន្លោះផ្សារដើមគរនិងបា មាន់ចែ។[3]

លោកបានចូលជាសមាជិកអ្នកនិពន្ធខ្មែរ នៅថ្ងៃ២កម្ភៈ១៩៥៨។ លោកបានជាប់ជាសមាជិកក្រុមអភិបាលសមាគមនេះជាច្រើនលើកច្រើនគ្រាផងដែរ។

នៅឆ្នាំ១៩៦៧លោកបានបង្កើតសារពត៌មាន កោះសន្តិភាពសហការជាមួយលោកសុទ្ធប៉ូលីនហើយលោកជាចាងហ្វាងនិងនិពន្ធនាយកកាសែតនេះ។[4]

លោកដួថានីបានសរសេរវិចារណកថាកាសែត កោះសន្តិភាពនេះ ហើយបានតែងនិពន្ធរឿងប្រលោមលោកជា ច្រើនដូចជា៖

១. នារីក្បាក់ខ្លួន, ភ្នំពេញ, ១៩៥៦, ១១៨ទំព័រ។

២. ស្នេហាជាតិ, ភ្នំពេញ, ១៩៥៦, ២៧៥ទំព័រ។

៣. មន្តស្នេហ៍ប្រែជាពឹស, ភ្នំពេញ, ១៩៥៦, ១៦២ទំព័រ។

៤. ដួសដុលជីវិត, ភ្នំពេញ, ១៩៥៦, ៩១ទំព័រ។

---

ពត៌មាននេះបានទទួលពីបណ្ឌិតសភាចារ្យ រស់ចន្ទ្រាបុត្រ ដែលធ្លាប់ជាអ្នកជំនិតនឹងទ្រង់ចន្ទរ័ង្សីកាលលោកមានឋានន្តរសក្តិជាអនុសេនីយឯកក្នុងវរសេនាធំលេខ១៣ក្រោមមេបញ្ជាការទ្រង់ចន្ទរ័ង្សីនេះ។ សូមអរគុណបណ្ឌិតសភាចារ្យនេះ។

[3] តាមសំដីលោកហេងអ៊ីវដួ។

[4] នៅឆ្នាំ១៩៦៧ បណ្ឌិតសភាចារ្យ រស់ចន្ទ្រាបុត្រ ក៏បានបង្កើតកាសែតមួយដែរ ឈ្មោះ"មហាជន"។ ពត៌មាននេះបានមកពីបណ្ឌិតសភាចារ្យ នេះផ្ទាល់។សូមអរគុណលោក។

៥. បុរសភ្ញាក់ខ្លួន, ភ្នំពេញ, ១៩៥៦, ៨៧ទំព័រ។

៦. ចាំជាតិក្រោយណាអូន, ភ្នំពេញ, ១៩៥៦, ៩៧ទំព័រ។

៧.មិនយកប្ដីចាស់, ភ្នំពេញ, ១៩៥៦, ៩០ទំព័រ។

៨. លះបង់ទាំងអាល័យ, ភ្នំពេញ, ១៩៥៦, ១៨០ទំព័រ។

៩. ល្អមើលណាស់, ភ្នំពេញ, ១៩៥៦, ៦៦ទំព័រ។

១០. សង្ឃឹមជានិច្ច, ភ្នំពេញ, ១៩៥៦, ៩៣ទំព័រ។

១១. ភ្លើងតណ្ហា, ភ្នំពេញ, ១៩៥៨, ១២០ទំព័រ។

១២. ជាតិនេះរងកម្ម, ភ្នំពេញ, ១៩៥៨, ៨៥ទំព័រ។

១៣. ចំរៀងនាពេលរាត្រី, ភ្នំពេញ, ១៩៥៨, ៦៣ទំព័រ។

១៤. ព្រាត់គ្នាព្រោះក្រីក្រ, ភ្នំពេញ, ១៩៥៨, ១៣៣ទំព័រ។

១៥. ព្រហ្មលិខិតឥតមេត្តា, ភ្នំពេញ, ១៩៦៥, ១៣៨ទំព័រ។

១៦. កុំអាងទឹកប្រាក់, ភ្នំពេញ, ១៩៦៥, ១២៣ទំព័រ។

១៧. វិលវិញណាអូន, ភ្នំពេញ, ១៩៦៥។

១៨. គំនិតថ្មី, ភ្នំពេញ, ១៩៦៦, ១៥២ទំព័រ។[5]

---

[5] Cf. KHUON Sokhamphu, *Le roman khmer contemporain*, 1973, 56 p. C'est un papier pour la communication au XXIXe Congrès international des Orientalistes à Paris, 1973. Il est partiellement publié dans *Actes du XXIXe Congrès international des Orientalistes*. Section organisée par Pierre-Bernard Lafont, Asie du Sud-Est continentale, vol. 3, Paris, L'Asiatèque, 1976, pp.204-208 ; cf. *Catalogue des auteurs et des livres publiés au Cambodge*, Phnom-Penh, Bibliothèque de l'Association des Ecrivains khmers, 1966, 24 p. ; ម៉ុញ-សារី, សទ្ទានុក្រមអក្សរសិល្ប៍ខ្មែរ, ភ្នំពេញ, ៣៣៦ទំព័រ, ឃីងហុកឌី, *អក្សរសិល្ប៍ខ្មែរសតវត្សទី២០- កវីនិពន្ធនិងកម្រងអត្ថប (Littérature cambodgienne du XXe siècle. Ecrivains et textes)*, ភ្នំពេញ, បណ្ណាគារអង្គរ, ២០០៧, ៦១២ទំព័រ។

*នាវវាងឆ្នាំ១៩៧០ ១៩៧១ សម័យសាធារណរដ្ឋខ្មែរ លោកដូថានីបានចុះផ្សាយក្នុងកាសែត កោះសន្តិភាព ជាវគ្គៗ* (Episodes) *មានចំនួនច្រើនវគ្គ នូវ រឿងមួយមានចំណងជើងថា"ពានរាំង" គឺជារឿងដែលមានទំនាក់ទំនងនឹង ព្រឹត្តិការណ៍នយោបាយជំនាន់នោះ។*

*ក្នុងចំណោមប្រលោមលោកនិពន្ធដោយលោកដូថានីសង្កេតឃើញប្រលោមលោកបែប មនោសញ្ចេតនា មាន៩រឿង ("ដួសដុលជីវិត", "ចាំជាតិក្រោយណាអូន", "មិនយកប្ដីចាស់", "លះបង់ទាំងអាល័យ", "ល្អមើលណាស់", "ចំរៀងនាពេលរាត្រី", "ព្រាត់គ្នាព្រោះក្រីក្រ", "ព្រហ្មលិខិតឥតមេត្តា", "វិលវិញណាអូន")។ ប្រលោមលោកបង្ហាញពីលក្ខណៈរិះគន់ទិទៀនមាន៣រឿង ("នារីភ្ញាក់ខ្លួន", "ស្នេហាជាតិ", "មន្តស្នេហ៍ប្រែជាពឹស")។ ប្រលោមលោកបង្ហាញពីសង្គមមាន២រឿង("ជាតិនេះរងកម្ម", "កុំអាងទឹកប្រាក់")។ ប្រលោមលោកមានលក្ខណៈជាប់នឹងជីវិតផ្ទាល់អ្នកនិពន្ធមាន២រឿង("បុរសភ្ញាក់ខ្លួន", "សង្ឃឹមជានិច្ច")និងប្រលោមលោកមានលក្ខណៈបែបចិត្តសាស្ត្រមាន១រឿង("គំនិតថ្មី")។*

# ឧបសម្ព័ន្ធ




ផ្សាយដំបូងនៅឆ្នាំ១៩៥៦។




ផ្សាយដំបូងនៅឆ្នាំ១៩៦៦។